សមាជិក សមាជិកា
នៃគណៈកម្មាធិការនាយក
សមាគមជនរងគ្រោះដោយ
របបកម្ពុជាប្រជាធិបតេយ្យ

1-លោក ជុំ ម៉ី : ប្រធាន

2-លោក ជុំ ស៊ីរ៉ាត:អនុប្រធានទី1

3-លោក ប៊ូ ម៉េង : អនុប្រធានទី 2

4-លោក ឆាត គឹមឈុន:

ប្រធានរដ្ឋបាល

5- លោក អ៊ុច ស៊ុនឡាយ

អនុប្រធានរដ្ឋបាល

6- លោកស្រី ភឹង ហ៊ុតស៊ុនថារី:

ប្រធានហិរញ្ញិក

7- លោកស្រី ជុំ នៅ

អនុប្រធានហិរញ្ញិក

8- លោក ស៊ាងវ៉ាន់ឌី :

ប្រធានកម្មវិធី

9- លោកស្រី កាន់ សុន្ទរ៉ា:

អនុប្រធានកម្មវិធី


# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## សមាគមជនរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ (គ្សេមក្សាន្ត)

## VICTIMS ASSOCIATION OF KAMPUCHEA DEMOCRATIC (KSAEM KSAN)

ភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១

### សេចក្តីថ្លែងការណ៍ពត៌មាន

សមាគមជនរងគ្រោះដោយកម្ពុជាប្រជាធិបតេយ្យ"គ្សេមក្សាន្ត"សូមសម្តែងសេចក្តីភ្ញាក់ផ្អើលរបស់ខ្លួនពាក់ពន្ធ័នឹងសេចក្តីថ្លែងការណ៍ ចុងក្រោយនៃការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពី ការលាលែងចេញពីដំណែងរបស់បុគ្គលិក នៃការិយាល័យ នេះ ។

ក្នុងស្ថាប័នណាក៏ដោយ ការចូល/ការលាលែងតំណែង គឺជារឿងសាមញ្ញ ។ អ្វីដែលជាការបារម្ភនោះគឺ សេចក្តីថ្លែងការណ៍នៃការិយាល័យសហចៅក្រមស៊ើបអង្កេតចេញពេលល្ងាចថ្ងៃអាទិត្យបន្ទាប់ពីមានការលាលែងច្រើនសប្តាហ៍មកកន្លង ហើយបានផ្តោតអារម្មណ៍ខុសពីធម្មតា ចំពោះការលាលែងតំណែងរបស់បុគ្គលិកខ្លួន ។ ស្ថានភាពនេះនាំឲ្យមានការងឿងឆ្ងល់ ចំពោះគោលបំណងនៃសេចក្តីថ្លែងការណ៍នេះ និងបង្កើត ឲ្យមានក្តីបារម្ភចំពោះការងារដែល បានធ្វើកន្លង ដោយខ្វះតម្លាភាព ។

ប៉ុន្មានថ្ងៃចុងក្រោយនេះ យើងខ្ញុំ សង្កេតឃើញថាមានការបែកធ្លាយនៃទំនាស់ផ្ទៃក្នុងនៅអ.វ.ត.កលើសង្វៀនសារធារណៈនេះ ។ យើងខ្ញុំ សូមសម្តែងក្តីបារម្ភខ្ពស់បំផុតចំពោះដំណើរការទៅមុខនៃសំណុំរឿង០០២ បណ្តឹងសារទុក្ខនៃ សំណុំរឿង០០១ និង ការដោះស្រាយសំណុំរឿង ០០៣ និង ០០៤ ។ និយាយដោយខ្លី យើងខ្ញុំខ្លាចថា ទំនាស់ផ្ទៃក្នុងនេះ អាចធ្វើឲ្យដំណើរការសាលាក្តីទាំងមូល មិនរលូន ដែលជាហេតុនាំមានភាព អយុត្តិធម៌ ចំពោះជនរងគ្រោះដែលរងចាំអស់រយៈពេលយ៉ាងយូរ និងបង្កើត នូវកេរ្តិ៍ដំណែលនៃភាពគ្មានប្រសិទ្ធភាពចំពោះការងារនៅ តុលាការគាំទ្រដោយអង្គការសហប្រជាជាតិ មួយនេះ ។

ក្នុងន័យនេះយើងខ្ញុំ សូមអំពាវនាវដល់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយធ្វើយ៉ាងណាដើម្បីធ្វើស្តារឡើងវិញ នូវភាពទំនុកទុកចិត្តរបស់ជនរងគ្រោះលើសាលាក្តីខ្មែរក្រហមនេះ ។

**ជ.គណៈកម្មាធិការនាយក**

*ជុំ ម៉ី ជុំ ស៊ីរ៉ាត*


អាស័យដ្ឋានទំនាក់ទំនង ផ្ទះលេខ ៦១ A ផ្លូវលេខ ៦០៨ សង្កាត់ បឹងកក់ II ខណ្ឌ ទួលគោក រាជធានី ភ្នំពេញ

www.ksemksan.org / Email : info@ksemksan.org ទូរសព្ទ័លេខ.(855) 12 71 21 48 / (855)12 81 29 68